សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីការជិះម៉ូតូឌុប ដែលរូបភាពទី ១
យើងឃើញមានស្ត្រីម្នាក់ដែលគាត់ស្លៀកពាក់ដូចជាអ្នកធ្វើការ គាត់ពាក់អាវ គាត់ពាក់អាវខៀវដៃវែង
និងសំពត់ពណ៌សត្រឹមជង្គង់ជាមួយនឹងស្បែកជើងពណ៌ខ្មៅ។
គាត់ស្ពាយកាបូបពណ៌សនៅចំហៀងស្មាខាងស្តាំរបស់គាត់
ដោយដៃរបស់គាត់កាន់កាបូបនោះយ៉ាងជាប់ ពីព្រោះដោយសារតែគាត់ដើរលឿន
ដូច្នេះគាត់មិនចង់ឲ្យកាបូបដែលស្ពាយនៅលើស្មាខាងស្តាំរបស់គាត់រអិលធ្លាក់ចុះទៅខាងក្រោមទេ។
អញ្ចឹងយើងឃើញនូវដៃខាងឆ្វេង ដៃខាងឆ្វេងរបស់គាត់
មានពាក់នាឡិកាដោយប្រើសម្រាប់មើលម៉ោង អញ្ចឹងគាត់ដើរបណ្តើរ ស្លឹងមើលនាឡិកានោះបណ្តើរ
ប្រហែលជាគាត់យឺត ឬក៏ប្រហែលជាគាត់ជ្រុលម៉ោង ដូច្នេះគាត់ត្រូវដើរ គាត់ត្រូវដើរយ៉ាងលឿន
ឬក៏គាត់ដើរយ៉ាងប្រញាប់ប្រញាល់ដើម្បីទៅដល់កន្លែងឲ្យទាន់ពេលវេលា អញ្ចឹងគាត់ដើរបណ្តើរ
ស្លឹងមើលបណ្តើរ ស្លឹងមើលម៉ោងបណ្តើរ ប្រហែលជាគាត់រវល់នៅផ្ទះ ឬក៏ប្រហែលជាគាត់គេងជ្រុល
ដូច្នេះធ្វើឲ្យគាត់យឺត ធ្វើឲ្យគាត់យឺតក្នុងការទៅធ្វើការ ឬក៏យឺតក្នុងការជួបជាមួយនឹង
ជួបជាមួយនឹងភ្ញៀវ។ ដោយសារតែអ្នកធ្វើការគឺត្រូវគោរពពេលវេលា
ដូច្នេះគាត់ត្រូវប្រញាប់ប្រញាល់ដើម្បីកុំឲ្យហួសពេល ឬក៏ដើម្បីកុំឲ្យយឺត ដើម្បីកុំឲ្យទៅដល់កន្លែង
កន្លែងធ្វើការ ឬក៏កន្លែងដែលគាត់ណាត់ជួបភ្ញៀវយឺត។ អញ្ចឹងគាត់ត្រូវដើរយ៉ាងលឿន
និងប្រញាប់ប្រញាល់។

នឹងរូបភាពទី ២ រូបភាពទី ២ ដោយសារតែជិតដល់ម៉ោង គាត់ក៏សម្រេចចិត្តរត់យ៉ាងលឿន
គាត់ក៏សម្រេចចិត្តរត់យ៉ាងលឿន ដើម្បីឲ្យទៅដល់កន្លែងទាន់ពេលវេលា។
អញ្ចឹងដោយសារតែយើងឃើញនៅតាមផ្លូវ មានឡានចំនួន ៣ ជួរ មិនអាចបើកទៅមុខបាន
ដោយសារតែមានការស្ទះចរាចរណ៍ខ្លាំងពេក។ ជាទូទៅស្ទះចរាចរណ៍ខ្លាំងគឺភាគច្រើននៅពេលព្រឹក
នៅពេលដែលមនុស្សចេញពីផ្ទះទៅធ្វើការ និងពេលល្ងាចជាពិសេសគឺនៅពេលដែលម៉ោង ៥ ឬក៏ ៥
កន្លះ ឬក៏ ៥ កន្លះ នៅពេលដែលមនុស្សចេញពីកន្លែងធ្វើការត្រលប់ទៅផ្ទះវិញ
ក៏មានការកកស្ទះចរាចរណ៍ផងដែរ។ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ២
ស្ត្រីម្នាក់នោះគាត់មិនអាចហៅឡានតាក់ស៊ីជិះបានទេ។ ដោយសារតែប្រសិនបើជិះឡានតាក់ស៊ី
ធ្វើឲ្យគាត់កាន់តែយឺត ដោយសារតែឡានមិនអាច មិនអាចបើកទៅមុខបាន
ដោយសារតែមានការស្ទះចរាចរណ៍ខ្លាំងពេក
ដូច្នេះគាត់ត្រូវរត់ដើម្បីអាចទៅដល់កន្លែងឲ្យទាន់ពេលវេលា។

រូបភាពទី ៣ រូបភាពទី ៣ គាត់រត់រហូតមកដល់កន្លែងមួយ ដែលយើងឃើញកន្លែងនោះ
យើងឃើញមានម៉ូតូជាច្រើនចតនៅទីនោះ។ ដែលមាន ដែលម៉ូតូទាំងអស់នោះគឺជាម៉ូតូឌុប

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺជាម៉ូតូឌុប។ ដែលម៉ូតូឌុបគឺឈរនៅក្រោមដំបូលដែលមានប្រក់ក្បឿង ឬក៏ស័ង្កសី
ដោយដំបូលនោះគឺសម្រាប់ការពារពន្លឺថ្ងៃ ឬក៏ការពារនៅពេលដែលមានភ្លៀង
អញ្ចឹងយើងឃើញម៉ូតូឌុប បាន ម៉ូតូឌុបគឺចតនៅក្រោមដំបូលនោះ ដោយយើងឃើញមានបុរសម្នាក់
គាត់គឺជា គាត់គឺជាម៉ូតូឌុប ដោយម៉ូតូរបស់គាត់យើងឃើញមានពណ៌ យើងឃើញមានពណ៌ក្រហម
យើងឃើញមានពណ៌ក្រហម និងម៉ូតូរបស់គាត់មានកង់ចំនួន២។ កង់មុខ កង់ខាងមុខ ១
កង់ខាងក្រោយ ១ និងនៅខាងមុខម៉ូតូគាត់ក៏មានចង្កៀង ឬក៏ភ្លើងសម្រាប់បំភ្លឺផ្លូវនៅពេលយប់ងងឹត
ឬក៏នៅពេលដែលមានភ្លៀងខ្លាំងពិបាកធ្វើដំណើរ គាត់អាចបើកភ្លើងនោះជាសញ្ញា
ឬក៏គាត់អាចបើកភ្លើងនោះ ដើម្បីបំភ្លឺផ្លូវងាយស្រួលបើកនៅពេលដែលមេឃងងឹត
ឬក៏នៅពេលដែលមានមេឃភ្លៀងខ្លាំង និងយើងឃើញម៉ូតូរបស់គាត់ក៏មានកញ្ចប់ ២
ដែលកញ្ចក់គឺប្រើសម្រាប់មើលក្រោយ អញ្ចឹងកញ្ចក់គឺប្រើសម្រាប់មើលក្រោយ
និងយើងឃើញនៅខាងក្រោយ និងខាងក្រោយកែបម៉ូតូរបស់គាត់
យើងឃើញមានមួកការពារសុវត្ថិភាពពណ៌លឿង ១ ដាក់នៅខាងក្រោយនោះ។
មួកការពារសុវត្ថិភាពគឺយើងពាក់នៅលើក្បាលរបស់យើង គឺការពារនៅពេលដែលយើងដួល
វាអាចជួយការពារក្បាលរបស់យើងបាន អញ្ចឹងជាទូទៅជិះម៉ូតូ យើងត្រូវ ជិះម៉ូតូ
ម៉ូតូយើងត្រូវមានកញ្ចក់សងខាងដែលអាចមើលផ្លូវខាងក្រោយបាន និងត្រូវពាក់មួកសុវត្ថិភាព
និងត្រូវពាក់មួកសុវត្ថិភាព ឬក៏មួកការពារជានិច្ច ដើម្បី ដើម្បីជួយ ជួយការពារក្បាលរបស់យើង
នៅពេលដែលយើងជួបនឹងគ្រោះថ្នាក់ដួល ឬក៏នៅពេលដែលមានឡានបុកពីក្រោយយើង
ដូច្នេះនៅពេលដែលយើងដួល មួកការពារសុវត្ថិភាពអាចការពារក្បាលរបស់យើងបាន
អាចការពារក្បាលរបស់យើងបាន និងមួកការពារ និងមួកការពារសុវត្ថិភាព ក៏មានកញ្ចក់
ក៏មានកញ្ចក់ ប្រើសម្រាប់ការពារពន្លឺថ្ងៃ និងកញ្ចក់យើងអាច នៅពេលដែលយើងបើកបរ
យើងអាចបិទកញ្ចក់ ដូច្នេះ ដូច្នេះយើងអាចការពារកុំឲ្យធូលីដីហើរមកប៉ះនឹងភ្នែកយើងបាន
ឬក៏កុំឲ្យធូលីដីហើរមកចូលនៅក្នុងភ្នែករបស់យើងបាន។ ដោយសារតែនៅពេលដែលយើងបើកបរ
ប្រសិនបើមានមានធូលីដី ឬក៏សត្វល្អិតហើរមកបុកភ្នែករបស់យើង
ដូច្នេះធ្វើឲ្យយើងអាចជួបនឹងគ្រោះថ្នាក់ ឬក៏ធ្វើឲ្យយើងអាចដួលម៉ូតូបាន
ដោយសារតែនៅពេលដែលធូលីដី ឬក៏សត្វហើរមកបុកនឹងភ្នែកយើង
អាចធ្វើឲ្យយើងពិបាកបើកភ្នែក និងពិបាកមើលផ្លូវផងដែរ។
ដូច្នេះមួកការពារសុវត្ថិភាពគឺសំខាន់សម្រាប់អ្នកបើកបរម៉ូតូ
និងកញ្ចក់ដែលនៅសងខាងម៉ូតូក៏សំខាន់ដែរ។
ពីព្រោះអាចមើលពីក្រោយនៅពេលដែលមានម៉ូតូវ៉ាគ្នា នៅពេលដែលមានម៉ូតូ ឬក៏ឡានវ៉ាគ្នា
យើងអាចចៀស យើងអាចចៀស និងអាចការពារសុវត្ថិភាពយើងផងដែរ។
និងអាចការពារសុវត្ថិភាពយើងដែរ។ អញ្ចឹងកញ្ចក់និងមួកការពារគឺសំខាន់សម្រាប់អ្នកបើកបរម៉ូតូ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញបុរសដែលជាម៉ូតូឌុបនោះ ដែលជាអ្នក រត់ម៉ូតូនោះ ដែលយើងហៅថាម៉ូតូឌុប យើងឃើញគាត់ឈរ យើងឃើញគាត់ឈរផ្អែកទៅនឹង យើងឃើញគាត់ឈរផ្អែកទៅនឹងម៉ូតូរបស់គាត់ ដោយគាត់ដាក់ជើងគងលើគ្នា និងគាត់ឈរឱបដៃ កាត់ឈរឱបដៃផ្អែកនឹងម៉ូតូរបស់គាត់។ អញ្ចឹងយើងឃើញគាត់ឈរ នៅពេលដែល នៅពេលដែលឃើញស្ត្រីម្នាក់នោះគាត់ដើរមកដល់ ម៉ូតូ គាត់ព្យាយាម ម៉ូតូឌុបនោះព្យាយាមស្លឹងមើលទៅស្ត្រី នឹងហៅស្ត្រី ដើម្បី ដើម្បីជិះម៉ូតូរបស់គាត់។ អញ្ចឹងជាទូទៅម៉ូតូឌុប នៅពេលដែលឃើញភ្ញៀវ នៅពេលដែលឃើញភ្ញៀវ ឬក៏មនុស្សដើរឆ្លងកាត់ ដោយមានស្ពាយកាបូប អញ្ចឹងជាទូទៅគាត់តែងតែហៅ ពីព្រោះគាត់គិតថាប្រហែលជាគាត់ត្រូវការម៉ូតូ អញ្ចឹងប្រហែលជាគាត់ត្រូវការម៉ូតូឌុប ដើម្បីឌុបគាត់ពីកន្លែង កន្លែងមួយទៅកន្លែងមួយដែលគាត់ ដែលគាត់ចង់ទៅ។ និងម៉ូតូឌុបអត់ថ្លៃទេ និងម៉ូតូឌុបអត់ថ្លៃទេ។ និងយើងឃើញស្ត្រី ស្ត្រីម្នាក់នោះ នៅពេលដែលគាត់រត់មកដល់កន្លែងដែលមានម៉ូតូឌុបច្រើន គាត់ក៏បានឈប់មួយសន្ទុះ និងគាត់ និងគាត់ដកដង្ហើមយ៉ាង យ៉ាងលឿន ដោយសារតែគាត់ហត់នៅពេលដែលគាត់រត់ ជាទូទៅនៅពេលដែលយើងរត់ យើងដកដង្ហើមយ៉ាងលឿន ដោយសារតែយើងហត់ខ្លាំងពេក ដោយសារតែយើងហត់ខ្លាំងពេក និងអាចធ្វើឲ្យមានញើស និងអាចមានញើសធ្វើឲ្យទទឹកខោអាវយើងផងដែរ។ ដោយសារតែនៅពេលដែលយើងរត់ នៅពេលដែលយើងរត់ និងមានញើសហូរ និងមានញើសហូរ និងអាចធ្វើឲ្យទទឹកអាវរបស់យើង ឬក៏មានញើសនៅលើមុខរបស់យើង។ អញ្ចឹង ដោយសារតែគាត់រត់យ៉ាងលឿន ដូច្នេះ ធ្វើឲ្យ ដូច្នេះធ្វើ ដូច្នេះធ្វើឲ្យគាត់ហត់ និងមានញើស និងមានញើសហូរចុះមក និងមានញើសហូរចុះមកផងដែរ ដោយសារតែគាត់រត់លឿនពេក ដោយសារតែគាត់រត់និងបោះជំហានវែងៗ ដើម្បីឲ្យដល់កន្លែងរបស់គាត់ទាន់ពេលវេលា។ ប៉ុន្តែនៅពេលដែលគាត់មកដល់ មកដល់កន្លែងដែលមានម៉ូតូឌុប គាត់ក៏បានឈប់សម្រាកមួយភ្លែត និងស្លឹងទៅមើលម៉ូតូឌុប ប្រហែលជាគាត់ត្រូវការម៉ូតូនោះ ដើម្បីឌុបគាត់ទៅកន្លែង ទៅកន្លែងធ្វើការរបស់គាត់ ឬក៏កន្លែងដែលគាត់ត្រូវជួបភ្ញៀវរបស់គាត់ និងគាត់កាន់កាបូបដែលស្ពាយចំហៀងស្មាខាងស្តាំរបស់គាត់យ៉ាងជាប់ ពីព្រោះនៅពេលរត់ កាបូបនោះអាចរអិលធ្លាក់ចុះទៅខាងក្រោមបាន ប្រសិនបើយើងមិនបានកាន់វា។ អញ្ចឹងយើង អញ្ចឹងយើងឃើញគាត់កាន់កាបូបនោះយ៉ាងជាប់ បើទោះបីជាគាត់ស្ពាយនៅលើស្មាខាងស្តាំក៏ដោយ។ អញ្ចឹងគាត់ស្លឹងទៅមើលម៉ូតូឌុប។

បន្ទាប់មករូបភាពទី ៤ រូបភាពទី ៤ គាត់ក៏ដើរទៅនិយាយជាមួយនឹងអ្នកម៉ូតូឌុប ដោយយើងឃើញ យើងឃើញគាត់កាន់កាបូបដែលដាក់នៅលើ ដែលស្ពាយនៅចំហៀងខាងស្តាំរបស់គាត់។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់កាន់កាបូបនោះយ៉ាងជាប់កុំឲ្យកាបូបនោះរអិលធ្លាក់ចុះ និងដៃខាងឆ្វេងរបស់គាត់
គាត់កំពុងតែព្យាយាម គាត់កំពុងតែព្យាយាមចង្អុល
ដើម្បីប្រាប់ផ្លូវទៅអ្នកម៉ូតូឌុបពីកន្លែងដែលគាត់ចង់ទៅ អញ្ចឹងគាត់ពន្យល់ គាត់ពន្យល់ទៅអ្នកម៉ូតូឌុប
ដើម្បីឲ្យ ដើម្បីឲ្យម៉ូតូឌុប ឌុបគាត់ទៅកន្លែងនោះបាន។ អញ្ចឹងយើងឃើញបុរសដែលជិះម៉ូតូឌុប
យើងឃើញគាត់ឈរឱបដៃ យើងឃើញគាត់ឈរឱបដៃ និងគាត់ពាក់អាវសដៃខ្លី គាត់ពាក់អាវសដៃខ្លី
និងខោជើងវែងពណ៌ស អញ្ចឹងម៉ូតូឌុបកំពុងតែស្តាប់ កំពុងតែឈរស្តាប់ស្ត្រីម្នាក់នោះ
គាត់ព្យាយាមពន្យល់ផ្លូវដែលគាត់ចង់ទៅ។

បន្ទាប់មកទៀត រូបភាពទី ៥ រូបភាពទី ៥ នៅពេលដែលស្ត្រីនោះព្យាយាម
ព្យាយាមប្រាប់ផ្លូវទៅកាន់អ្នកម៉ូតូឌុប អ្នកម៉ូតូឌុបក៏ ក៏គាត់យល់ ដោយសារតែអ្នកម៉ូតូឌុប
គាត់ជិះសឹងតែ គាត់ជិះសឹងតែគ្រប់ផ្លូវ ឬក៏គាត់ស្គាល់សឹងតែគ្រប់ផ្លូវ
ដូច្នេះនៅពេលដែលភ្ញៀវពន្យល់ប្រាប់អំពីទីតាំង ឬក៏លេខផ្លូវ គាត់អាចដឹងកន្លែងនោះយ៉ាងច្បាស់។
អញ្ចឹងយើងឃើញអ្នកម៉ូតូឌុបនៅពេលដែលស្តាប់ស្ត្រី ពន្យល់អំពីទីតាំងដែលគាត់ត្រូវទៅ គាត់ក៏បាន
គាត់ក៏បាន គាត់ក៏បានបញ្ជាក់ទីតាំងជាមួយនឹងស្ត្រីនោះម្តងទៀត ដើម្បីឲ្យកាន់តែច្បាស់
ដែលយើងឃើញ ដែលយើងឃើញដៃខាងស្តាំរបស់គាត់ ដៃខាងស្តាំរបស់គាត់ព្យាយាមធ្វើកាយវិការ
ធ្វើកាយវិការ ដើម្បីបង្ហាញផ្លូវ ដើម្បីបញ្ជាក់ផ្លូវឲ្យកាន់តែច្បាស់
ក្រោយពេលដែលស្ត្រីម្នាក់នោះគាត់ព្យាយាម គាត់ព្យាយាមពន្យល់ប្រាប់ផ្លូវនោះ។
អញ្ចឹងយើងឃើញនៅពេលដែលបុរសនោះកំពុងតែ កំពុងតែបញ្ជាក់ផ្លូវនោះម្តងទៀត
យើងឃើញស្ត្រីម្នាក់នោះគាត់ គាត់ គាត់ញញឹម គាត់ឈរដោយទឹកមុខញញឹម
ដោយសារតែនៅពេលដែលគាត់ប្រាប់ផ្លូវ អ្នកម៉ូតូឌុបយល់ពីទីតាំងដែលគាត់ត្រូវទៅ
ដូច្នេះគាត់ក៏សម្រេចចិត្តជិះម៉ូតូឌុប គាត់ក៏សម្រេចចិត្តជិះម៉ូតូឌុប។

រូបភាពទី ៦ រូបភាពទី ៦ ម៉ូតូឌុបក៏បាន ក៏បានទៅយកមួកការពារសុវត្ថិភាពរបស់គាត់ពណ៌លឿង
ពាក់នៅលើក្បាលរបស់គាត់ និងគាត់បើកកញ្ចក់ឡើងទៅលើ
ដោយសារតែគាត់មិនទាន់ជិះនៅលើម៉ូតូ ដូច្នេះគាត់ត្រូវបើកកញ្ចក់
ដើម្បីនិយាយជាមួយនឹងស្ត្រីម្នាក់នោះ អញ្ចឹងគាត់ ក្រោយពេលដែលគាត់ពាក់មួកហើយ គាត់ត្រូវកិប
គាត់ត្រូវកិបមួកនោះ មានន័យថាមួកការពារសុវត្ថិភាព
នៅពេលដែលយើងពាក់ក៏មានខ្សែសម្រាប់កិបគន្លឹះរបស់វាផងដែរ។
ពីព្រោះនៅពេលដែលយើងជិះម៉ូតូលឿន ប្រសិនបើយើងជិះម៉ូតូលឿន និងយើងអត់បានកិបនូវខ្សែ
និងខ្សែគន្លឹះរបស់មួកការពារនោះទេ។ អាចធ្វើឲ្យមួកការពារនោះប៉ើងរបូតធ្លាក់ចុះទៅខាងក្រោមបាន
និងនៅពេលដែលដួល អាចធ្វើឲ្យមួកនោះប៉ើងចេញពីក្បាលរបស់យើង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងអាចធ្វើឲ្យយើងមានគ្រោះថ្នាក់រហូតដល់ជីវិតផងដែរ។ និងជាទូទៅ
ប្រសិនបើយើងអត់ពាក់មួកសុវត្ថិភាព ប៉ូលិសនឹងផាកពិន័យយើងផងដែរ។
នឹងប្រសិនបើអត់មានកញ្ចក់ម៉ូតូ ប៉ូលិសក៏អាចផាកពិន័យយើងផងដែរ។
ដោយសារតែយើងមិនបានគោរពច្បាប់ មិនបានពាក់មួកសុវត្ថិភាពនៅពេលដែលបើកបរ
ឬក៏ម៉ូតូអត់មានកញ្ចក់សម្រាប់មើលក្រោយ។ ជាទូទៅម៉ូតូគឺយើងប្រើមួកការពារសុវត្ថិភាពនិងកញ្ចក់
ប្រសិនបើឡាន ជាទូទៅនៅពេលដែលយើងបើកឡាន យើងត្រូវពាក់ខ្សែក្រវាត់ការពារ
ការពារសុវត្ថិភាពយើង។ អញ្ចឹងនៅពេលដែលយើងបុកជាមួយនឹងអ្វីមួយ ខ្សែក្រវាត់នោះអាច
អាចជួយយើងបាន អញ្ចឹងឡាន
អញ្ចឹងជាទូទៅយើងជិះឡានយើងត្រូវពាក់ខ្សែក្រវាត់នៅចំហៀងខ្លួនរបស់យើង
និងនៅពេលដែលយើងជិះម៉ូតូយើងត្រូវពាក់ ពាក់មួកការពារ
ឬក៏មួកការពារសុវត្ថិភាពជាមួយនឹងកញ្ចក់ម៉ូតូទាំងសងខាង
ដើម្បីងាយស្រួលក្នុងការមើលខាងក្រោយ នៅពេលដែលយើងបើកម៉ូតូនៅតាមផ្លូវ
អញ្ចឹងបុរសដែលជាអ្នកម៉ូតូឌុបនោះ គាត់បានយកមួកការពារមួយទៀត ដើម្បីឲ្យស្ត្រីម្នាក់នោះពាក់
ដើម្បីឲ្យស្ត្រីរបស់ ដើម្បីឲ្យស្ត្រីម្នាក់នោះពាក់ ដើម្បីការពារ ដើម្បីការពារក្បាលរបស់គាត់
បើទោះបីជាគាត់គឺជាអ្នកជិះនៅខាងក្រោយក៏ដោយ ប៉ុន្តែគាត់ត្រូវពាក់មួកការពារដូចជា
ដូចជាអ្នកឌុបដែរ ដោយសារតែ ដូចជាអ្នកបើកម៉ូតូដែរ។ ដោយសារតែ
បើទោះបីជាយើងជិះនៅខាងក្រោយ ប្រសិនបើយើងដួលក៏អាចមានគ្រោះថ្នាក់ផងដែរ
ដូច្នេះអ្នកជិះនៅខាងមុខ អ្នកជិះ និងអ្នកជិះនៅខាងក្រោយត្រូវពាក់មួកសុវត្ថិភាពដូចគ្នា
ប៉ុន្តែស្ត្រីម្នាក់នោះ ហាក់បីដូចជាមិនត្រូវការពាក់មួកសុវត្ថិភាពនោះទេ ដោយសារតែគាត់ប្រញាប់
ដើម្បី ដោយសារតែគាត់ប្រញាប់ និងប្រហែលជាគាត់អត់ចូលចិត្តមួកការពារសុវត្ថិភាព
ពីព្រោះពេលខ្លះនៅពេលដែលយើងពាក់មួកសុវត្ថិភាព អាចធ្វើឲ្យសក់យើងអត់ស្អាត
ដោយសារតែសក់យើងរាបស្មើ ដោយសារតែសក់យើងរាបស្មើ អញ្ចឹងនៅពេលដែលយើងចងសក់
ឬក៏នៅពេលដែលយើងធ្វើម៉ូតសក់ ជាទូទៅនៅពេលដែលយើងពាក់មួក អាចធ្វើឲ្យសក់យើងខូចបាន
អញ្ចឹងអាចធ្វើឲ្យសក់យើងខូចបាន អញ្ចឹងអ្នកខ្លះគាត់អត់ចូលចិត្តពាក់មួកទេ
ដោយសារតែគាត់អត់ចង់ឲ្យសក់គាត់ខូច ខូចម៉ូតដែលគាត់ធ្វើ ឬក៏ដោយសារតែគាត់អត់ចូលចិត្ត
អត់ចូលចិត្តមួកសុវត្ថិភាព
ពីព្រោះនៅពេលដែលពាក់អាចធ្វើឲ្យគាត់មានញើសនៅលើក្បាលរបស់គាត់
និងអាចធ្វើឲ្យគាត់រមាស់ក្បាលផងដែរ។ អញ្ចឹងបានជាស្ត្រីនោះគាត់អត់ចង់ពាក់មួកនោះ
ឬក៏ប្រហែលជាគាត់ដល់ម៉ោង អញ្ចឹងគាត់មិនចាំបាច់ពាក់មួកការពារសុវត្ថិភាពនោះទេ
ឬក៏គាត់គិតថាគាត់គ្រាន់តែអ្នកជិះនៅខាងក្រោយ អញ្ចឹងក៏មិនចាំបាច់ពាក់មួកសុវត្ថិភាពនោះដែរ។
បើទោះបីជាអ្នកម៉ូតូឌុបព្យាយាមពន្យល់ប្រាប់ ដើម្បីឲ្យស្ត្រីនោះពាក់មួកការពារសុវត្ថិភាព

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប៉ុន្តែគាត់នៅតែបដិសេធមិនពាក់មួកសុវត្ថិភាពនោះ បន្ទាប់មកម៉ូតូឌុបក៏គាត់ ក៏គាត់មិន ក៏គាត់ឈប់ ក៏គាត់ធ្វើតាមស្ត្រីម្នាក់នោះ ក៏គាត់ធ្វើតាមស្ត្រីម្នាក់នោះ ពីព្រោះគាត់ព្យាយាមប្រាប់ឲ្យស្ត្រីម្នាក់នោះពាក់មួក ប៉ុន្តែស្ត្រីម្នាក់នោះអត់ស្តាប់គាត់ ដូច្នេះគាត់ក៏ធ្វើតាមអ្វីដែលស្ត្រីម្នាក់នោះចង់បាន។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ ស្ត្រីម្នាក់នោះក៏ឡើងជិះម៉ូតូនៅខាងក្រោយ អញ្ចឹងមានន័យថាអ្នកឌុបគឺជិះនៅខាងមុខ អ្នក អ្នកឌុបជិះនៅខាងមុខ អ្នក អ្នកឌុបគឺជិះនៅខាងមុខ និងអ្នកដែលជិះគឺ និងអ្នកដែលជិះគឺជិះនៅខាងក្រោយ អ្នកដែល អ្នកដែលជិះខាង អ្នកដែលជិះគឺជិះនៅខាងក្រោយ អញ្ចឹងអ្នកឌុបជិះនៅខាងមុខ អ្នកជិះខាងក្រោយមានម្នាក់ អ្នកឌុបមានម្នាក់ អញ្ចឹងស្ត្រីម្នាក់នោះយើងឃើញគាត់ជិះចំហៀង ជិះចំហៀង និងដោយសារតែគាត់ ដោយសារតែគាត់ស្លៀកសំពត់ ដូច្នេះគាត់ពិបាកជិះច្រកកៀរ។ ជិះច្រកកៀរមានន័យថា គាត់ត្រូវជិះដាក់ជើងម្ខាងនៅខាងឆ្វេង ដាក់ជើងម្ខាងនៅខាងស្តាំ ដាក់ជើងម្ខាងនៅខាងស្តាំ គាត់អត់អាចជិះដាក់ជើងជាប់គ្នាដូច ដូចនៅក្នុងរូបភាពទី ៧ នេះបានទេ។ ដោយសារតែ ប៉ុន្តែដោយសារតែគាត់ស្លៀកសំពត់ ដូច្នេះគាត់ពិបាកនឹងជិះច្រកកៀរ អញ្ចឹងគាត់ត្រូវការជិះចំហៀង និងបន្ទាប់មកយើងឃើញកាបូបរបស់គាត់គឺដាក់នៅលើ នៅលើភ្លៅរបស់គាត់ អញ្ចឹងគាត់ដោះកាបូបរបស់គាត់ចេញពីស្មាដែលគាត់ស្ពាយនៅលើស្មាខាងស្តាំរបស់គាត់ គាត់ក៏បានដោះកាបូបនោះយកមកដាក់នៅលើភ្លៅរបស់គាត់ និងដៃទាំង ២ របស់គាត់កាន់កាបូបនោះយ៉ាងជាប់។ អញ្ចឹងជាទូទៅមនុស្សស្រី ភាគច្រើននៅពេលដែលគាត់ស្លៀកសំពត់ គឺគាត់ជិះចំហៀង។ ប៉ុន្តែមនុស្សប្រុស គឺជាទូទៅ គឺជិះ គឺជិះច្រកកៀរ ដោយសារតែមនុស្សប្រុសគាត់ស្លៀកខោ គាត់ស្លៀកខោ និងជាទូទៅជិះច្រកកៀរ គឺសុវត្ថិភាពជាងជិះចំហៀង នៅពេលដែលយើងជិះចំហៀង ប្រសិនបើយើងមិនបានកាន់ម៉ូតូ ឬក៏មិនបានកាន់អ្នកបើកម៉ូតូឲ្យជាប់ទេ នៅពេលដែលម៉ូតូឈប់ ឬក៏ចាប់ហ្វ្រាំង អាចធ្វើឲ្យគាត់ដួល បោកក្បាលទៅខាងក្រោយបាន ប្រសិនបើគាត់មិនបានកាន់ម៉ូតូនោះជាប់ទេ អញ្ចឹងស្រីៗភាគច្រើនគាត់ចូលចិត្តជិះចំហៀង ពេលដែលគាត់ ជាពិសេសនៅពេលដែលគាត់ស្លៀកសំពត់ ប៉ុន្តែប្រុសៗគឺគាត់ជិះច្រកកៀរ គាត់ជិះច្រកកៀរ និងយើងឃើញអ្នកបើកម៉ូតូឌុប នៅពេលដែល[យើង] នៅពេលដែលគាត់បើកម៉ូតូ គាត់បិទកញ្ចក់មួកការពាររបស់គាត់ ដើម្បីការពារកុំឲ្យធូលីដី ឬក៏ពន្លឺថ្ងៃ ប៉ះត្រូវមុខ ឬក៏ប៉ះត្រូវភ្នែករបស់គាត់ និងម៉ូតូរបស់គាត់ក៏មានកញ្ចក់ ២ សងខាង ប្រើសម្រាប់មើលក្រោយផងដែរ។ អញ្ចឹងយើងឃើញគាត់បើកម៉ូតូយ៉ាងលឿន យើងឃើញគាត់បើកម៉ូតូយ៉ាងលឿន ដើម្បីអាចទៅដល់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីអាចទៅដល់ទីតាំងដែលស្ត្រីនោះចង់ទៅឲ្យទាន់ពេលវេលា
អញ្ចឹងដើម្បីបើកឲ្យទៅដល់ទាន់ពេលវេលា។

រូបភាពទី ៨ ដោយសារតែស្ទះចរាចរណ៍ខ្លាំងពេក ដូច្នេះគាត់ត្រូវប្រជ្រៀត គាត់ត្រូវជិះប្រជ្រៀត
ឬក៏គាត់ត្រូវជិះជ្រែឡាន គាត់ត្រូវជិះជ្រែឡាន មានន័យថា គាត់ត្រូវជិះ គាត់ត្រូវជិះកាត់ឡាននីមួយៗ
គាត់ជិះកាត់ឡាននីមួយៗដែលយើងហៅថាជិះជ្រែ ដើម្បីអាចទៅដល់ទីតាំងទាន់ពេលវេលា
ដោយយើង ដោយសារតែម៉ូតូរបស់គាត់តូច និងងាយស្រួលក្នុងការ ងាយស្រួលក្នុងការប្រជ្រៀត
ដូច្នេះជាទូទៅនៅពេលដែលស្ទះចរាចរណ៍ ម៉ូតូគឺអាចប្រជ្រៀតចេញបានមុនគេ
ប៉ុន្តែឡានជាទូទៅនៅពេលដែលស្ទះចរាចរណ៍មិនអាចបើកទៅមុខបានលឿនទេ។
ដោយសារតែឡានគឺមានរាងធំ និងកង់ឡានមានចំនួន ៤
ដូច្នេះរឿងពិបាកបន្តិចនៅពេលដែលស្ទះចរាចរណ៍ ប៉ុន្តែម៉ូតូវិញ ប៉ុន្តែម៉ូតូវិញគឺងាយស្រួល
អញ្ចឹងម៉ូតូគឺងាយស្រួល អញ្ចឹងយើងឃើញម៉ូតូរបស់គាត់គឺគាត់បើកលឿន គាត់បើកលឿន
គាត់ជ្រែឡាន គាត់ជ្រែឡាន និងយើងឃើញគាត់បើកកាត់ឡាន
ដើម្បីអាចទៅដល់កន្លែងដែលស្ត្រីនោះចង់ទៅឲ្យទាន់ពេលវេលា អញ្ចឹងយើងឃើញគាត់បើកលឿន
ប៉ុន្តែគាត់មានពាក់មួកការពារសុវត្ថិភាពនៅលើក្បាលរបស់គាត់។ ដូច្នេះមិន ដូច្នេះប្រសិនបើគាត់ដួល
ឬមានបញ្ហាអ្វី ក៏គាត់អាច ក៏គាត់មិនអាច ក៏គាត់អាច ក៏គាត់មិនអាចមានរបួសធ្ងន់ធ្ងរឡើយ
ជាពិសេសគឺក្បាលគាត់ ដោយសារតែគាត់មានមួកការពារ ការពារសុវត្ថិភាព
និងបើទោះបីជាបើកលឿន គឺមិន ធូលីដី ឬក៏សត្វល្អិតមួយចំនួន
មិនអាចហើរប៉ះភ្នែករបស់គាត់បានទេ ដោយសារតែមួករបស់គាត់គឺបិទកញ្ចក់
ដូច្នេះគាត់អាចមើលផ្លូវបានយ៉ាងងាយស្រួល អញ្ចឹងយើងឃើញម៉ូតូគាត់បើក បើកប្រជ្រៀត
ឬក៏បើកវ៉ាឡាន បើកវ៉ាឡាន អញ្ចឹងយើងឃើញគាត់បើកយ៉ាងលឿន និងស្ត្រីដែលជិះពីក្រោយនោះ
ដោយសារតែគាត់អត់មានពាក់មួកសុវត្ថិភាព និងដោយសារម៉ូតូបើកលឿនផង
ដូច្នេះយើងឃើញសក់របស់គាត់ប៉ើងដោយសារតែមានខ្យល់ ដោយសារតែខ្យល់ ដូច្នេះធ្វើឲ្យគាត់
ធ្វើឲ្យសក់របស់គាត់ប៉ើង។ អញ្ចឹងយើងឃើញស្ត្រីម្នាក់នោះគាត់អង្គុយចំហៀងនៅពីក្រោយ
និងដាក់កាបូបស្ពាយ និងដាក់កាបូបរបស់គាត់នៅលើភ្លៅរបស់គាត់
និងគាត់កាន់កាបូបនោះយ៉ាងជាប់នៅពេលដែលគាត់ជិះម៉ូតូ អញ្ចឹងយើងឃើញម៉ូតូឌុបនោះ
គឺព្យាយាមបើកប្រជ្រៀត បើកប្រជ្រៀត
ឬក៏វ៉ាឡានដើម្បីអាចឆាប់ទៅដល់គោលដៅឲ្យទាន់ពេលវេលា។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ នៅពេលដែលជិតដល់កន្លែងដែលត្រូវឈប់
ស្ត្រីម្នាក់នោះក៏បានចង្អុលប្រាប់ទៅម៉ូតូឌុប ដើម្បីឲ្យឈប់ចំកន្លែងដែលគាត់ចង់ឲ្យឈប់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលឈប់ចំកន្លែង ដែលគាត់ចង់ឈប់ ដោយយើងឃើញគាត់ជិះចំហៀង
និងដាក់កាបូបគាត់នៅលើភ្លៅរបស់គាត់ គាត់កាន់កាបូបនោះនៅក្នុងដៃខាងស្តាំរបស់គាត់
និងដៃខាងឆ្វេងគឺគាត់ចង្អុលប្រាប់ម៉ូតូឌុប ដើម្បីឲ្យឈប់ចំកន្លែងរបស់គាត់ អញ្ចឹងយើងឃើញ
យើងឃើញម៉ូតូឌុបបើកយ៉ាងលឿន វ៉ាំឡាន វ៉ាំឡាន ឬក៏ប្រជ្រៀតជាមួយនឹងឡាន
នៅទីបំផុតគាត់ក៏អាចមកដល់ គាត់ក៏អាចមកដល់ទីតាំងដែលភ្ញៀវរបស់គាត់ត្រូវការឈប់
ទីតាំងដែលភ្ញៀវរបស់គាត់ចង់ឈប់ អញ្ចឹងស្ត្រីម្នាក់នោះគឺគាត់ចង្អុលប្រាប់ នៅកន្លែងដែលគាត់ចង់
នៅកន្លែងដែលគាត់ចង់ឈប់ប្រាប់ទៅអ្នកម៉ូតូឌុប។

បន្ទាប់មកទៀតរូបភាពទី ១០ នៅពេលដែល
នៅពេលដែលស្ត្រីម្នាក់នោះចង្អុលទៅកន្លែងដែលគាត់ត្រូវឈប់ ម៉ូតូក៏បានឈប់
បន្ទាប់មកគាត់ក៏ទម្លាក់ជើងម្ខាង គាត់ក៏ទម្លាក់ជើងម្ខាង ដើម្បីទប់ទម្ងន់ម៉ូតូកុំឲ្យដួល
ដើម្បីទប់ទម្ងន់ម៉ូតូកុំឲ្យដួល ពីព្រោះដោយសារតែស្ត្រីម្នាក់នោះគាត់អង្គុយចំហៀង
ដូច្នេះអាចងាយស្រួលផ្អៀង អាចងាយស្រួលផ្អៀង និងអាចងាយស្រួលដួលបាន។
ដូច្នេះនៅពេលដែលឈប់ម៉ូតូ យើងត្រូវទម្លាក់ជើងដើម្បីទប់លំនឹងម៉ូតូនោះឲ្យនៅនឹង
ដើម្បីទប់លំនឹងម៉ូតូឲ្យនៅនឹង អញ្ចឹងនៅពេលដែលម៉ូតូនោះឈប់
ស្ត្រីម្នាក់នោះគាត់មិនទាន់ចុះនៅឡើយទេ ពីព្រោះគាត់រង់ចាំឲ្យម៉ូតូនោះឈប់ស្រួលបួលសិន
ឈប់ស្រួលបួលសិន និង ដូច្នេះគាត់អាចចុះដោយសុវត្ថិភាព ដូច្នេះគាត់អាចចុះដោយសុវត្ថិភាព
អញ្ចឹងក្រោយពេលដែលម៉ូតូឌុបនោះបានឈប់ ឬក៏មកដល់ទីតាំងដែលស្ត្រីនោះ គាត់ ដែលស្ត្រីនោះ
គាត់ ដែលស្ត្រីនោះបានប្រាប់គាត់ឲ្យឌុបមកទីនេះ ដូច្នេះគាត់ក៏បានឈប់ម៉ូតូ
និងទម្លាក់ជើងម្ខាងដើម្បីទប់ទម្ងន់ម៉ូតូកុំឲ្យដួល និងស្ត្រីម្នាក់នោះ ក្រោយពេលដែលឃើញម៉ូតូឈប់
គាត់ក៏រៀបចំចុះពីលើ ចុះពីលើកែបម៉ូតូ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ ស្ត្រីម្នាក់នោះគាត់ក៏បានចុះពីលើកែបម៉ូតូ
ដោយសារតែគាត់ជិះចំហៀង ដូច្នេះនៅពេលដែលគាត់ចុះគឺងាយស្រួល គាត់គ្រាន់តែទម្លាក់ជើង
និងអាចចុះមកខាងក្រោមបានដោយសុវត្ថិភាព។
អញ្ចឹងក្រោយពេលដែលស្ត្រីម្នាក់នោះគាត់ចុះពីលើម៉ូតូ
ម៉ូតូឌុបក៏បានឈប់ដើម្បីចាំឲ្យស្ត្រីម្នាក់នោះឲ្យលុយគាត់ ឲ្យលុយគាត់
អញ្ចឹងយើងឃើញគាត់ទម្លាក់ជើងម្ខាងទប់ម៉ូតូ
និងដៃរបស់គាត់ម្ខាងទៀតបានកាន់នូវកែបខាងក្រោយ នៅពេលដែលកាន់កែបខាងក្រោយ
នៅពេលដែលស្ត្រីនោះគាត់ចុះ អញ្ចឹងគាត់កាន់ និងងាកខ្លួនដើម្បីមើលស្ត្រីនោះចុះពីម៉ូតូ
និងដើម្បីរង់ចាំស្ត្រីនោះឲ្យលុយគាត់ និងគាត់ នៅពេលដែលគាត់ឈប់ម៉ូតូ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានបើកមួកសុវត្ថិភាព មានន័យថាគាត់បើកកញ្ចក់របស់មួកសុវត្ថិភាព ដើម្បីងាយស្រួល
ដើម្បីងាយស្រួលមើលស្ត្រីម្នាក់នោះចុះពីលើម៉ូតូ ឬក៏ដើម្បីងាយស្រួលមើលលុយ
នៅពេលដែលស្ត្រីម្នាក់នោះគាត់ហុចលុយឲ្យគាត់។ និង
និងយើងអាចបើកកញ្ចក់មួកការពារសុវត្ថិភាពនៅពេលដែលយើងឈប់
អញ្ចឹងយើងអាចឲ្យខ្យល់ចូលទៅក្នុងមួករបស់យើង អញ្ចឹងកុំឲ្យមានញើស កុំឲ្យ កុំឲ្យហប់ ឬក៏
កុំឲ្យហប់ និងកុំឲ្យមានញើស ពីព្រោះនៅពេលដែលយើងពាក់មួកការពារសុវត្ថិភាព
ពេលខ្លះមានអារម្មណ៍ថាក្បាលរបស់យើងហប់ ដោយសារតែអត់មានខ្យល់ចូលទៅខាងក្នុង
ដូច្នេះអាចធ្វើឲ្យយើងបែកញើស និងអាចរមាស់ក្បាលបាន ធ្វើឲ្យយើងបែកញើស
និងអាចរមាស់ក្បាលបាន ដូច្នេះគាត់អាចបើកកញ្ចក់ដើម្បីឲ្យខ្យល់ចូលទៅខាងក្នុង
ដើម្បីឲ្យខ្យល់ចូលទៅខាងក្នុង ឲ្យ ដើម្បីកុំឲ្យហប់ ឬក៏ដើម្បីកុំឲ្យ ដើម្បីកុំឲ្យមានញើស
កុំឲ្យមានញើសក្បាល។

អញ្ចឹងបន្តមកទៀតរូបភាពទី ១២ រូបភាពទី ១២ ក្រោយពេលដែលស្ត្រីម្នាក់នោះគាត់ចុះពីលើម៉ូតូ
ស្ត្រីម្នាក់នោះគាត់ក៏បានងាកខ្លួន និងដកកាបូបលុយចេញពីកាបូបស្ពាយចំហៀង
នៅស្មាខាងស្តាំរបស់គាត់ ដើម្បីឲ្យលុយទៅម៉ូតូឌុប
អញ្ចឹងយើងឃើញគាត់ស្ពាយកាបូបពណ៌សនៅចំហៀងស្មាខាងស្តាំរបស់គាត់
និងដៃរបស់គាត់កាន់កាបូបនោះយ៉ាងជាប់ កុំឲ្យរអិលធ្លាក់ចុះមកខាងក្រោម
និងដៃខាងឆ្វេងបានលូកយកកាបូបលុយ ដើម្បីដកលុយឲ្យម៉ូតូឌុប
និងអ្នកម៉ូតូឌុបក៏កំពុងតែអង្គុយរង់ចាំលុយរបស់ស្ត្រីម្នាក់នោះផងដែរ។
ដោយសារតែគាត់គឺជាអ្នកម៉ូតូឌុប គាត់ត្រូវ នៅពេលដែលគាត់ឌុបភ្ញៀវពីកន្លែងមួយទៅកន្លែងមួយ
គាត់នឹងបានលុយពីភ្ញៀវ ពីព្រោះដោយសារតែគាត់គឺជាម៉ូតូឌុប គាត់គឺជាអ្នកម៉ូតូឌុប
គាត់ត្រូវឌុបភ្ញៀវពីកន្លែងមួយទៅកន្លែងមួយ ទៅតាមភ្ញៀវ គាត់
ទៅតាមចិត្តភ្ញៀវដែលគាត់ចង់ទៅកន្លែងណា ដែលពួកគាត់ចង់ទៅ និងដូច្នេះយើងឃើញអ្នកម៉ូតូ
យើងឃើញម៉ូតូឌុបនោះគាត់កំពុងតែអង្គុយ គាត់កំពុងតែអង្គុយរង់ចាំ គាត់កំពុងតែអង្គុយរង់ចាំ
ស្ត្រីដែលគាត់ដកកាបូបចេញពីកាបូបស្ពាយចំហៀងរបស់គាត់ ដើម្បីបាន ដើម្បីចាំ
ដើម្បីបានលុយពីស្ត្រីម្នាក់នោះ។

រូបភាពទី ១៣ ក្រោយពេលគាត់ដកកាបូបលុយពីកាបូបស្ពាយចំហៀងពណ៌ស
នៅចំហៀងស្មាខាងស្តាំរបស់គាត់
ស្ត្រីម្នាក់នោះក៏បានហូតលុយចេញពីក្នុងកាបូបលុយរបស់គាត់ចេញមកខាងក្រៅ ដើម្បីឲ្យម៉ូតូឌុប
ដោយអាស្រ័យទៅលើតម្លៃ គឺអាស្រ័យទៅលើកន្លែងជិត ឬក៏កន្លែងឆ្ងាយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប្រសិនបើកន្លែងជិតអាចត្រឹម ៥ ពាន់រៀល ប្រសិនបើកន្លែងឆ្ងាយអាច ១ ម៉ឺនរៀល ឬក៏ ២ ម៉ឺនរៀល។ អញ្ចឹងជាទូទៅតម្លៃគឺទៅតាមកន្លែងដែលជិត ឬក៏ឆ្ងាយ អញ្ចឹងទៅតាមកន្លែងជិត ឬក៏ឆ្ងាយ អញ្ចឹងយើងឃើញស្ត្រីម្នាក់នោះបានហុចលុយឲ្យទៅម៉ូតូឌុប អញ្ចឹងម៉ូតូឌុបក៏បាន ក៏បានលាដៃ យក ក៏បានលាដៃ និងទទួល និងទទួលលុយពីស្ត្រីម្នាក់នោះ។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ ដោយសារតែលុយរបស់គាត់
ដោយសារតែលុយរបស់គាត់ ច្រើនជាងតម្លៃដែលគាត់ ច្រើនជាងតម្លៃដែលគាត់ទារ
ដូច្នេះគាត់ក៏បានអាប់លុយឲ្យទៅស្ត្រីម្នាក់នោះវិញ។ មានន័យថាប្រហែលជាគាត់
គាត់ទារថ្លៃប្រហែលជា ៥ ពាន់។
អញ្ចឹងយើងអត់ដឹងថានៅក្នុងរូបភាពនេះគាត់ជិះពីកន្លែងណាដល់កន្លែងណាទេ។
អញ្ចឹងយើងគ្រាន់តែស្មានថាប្រហែលជាគាត់ ប្រហែលជាគាត់គិត ប្រហែលជាគាត់យកលុយ ៥ ពាន់
៥ ពាន់ ដូច្នេះ ស្ត្រីម្នាក់នោះប្រហែលជាឲ្យ ស្ត្រីម្នាក់នោះ គាត់អត់មានលុយរាយ ប្រហែលជាគាត់ឲ្យ
ប្រហែលជាគាត់ឲ្យ ១ ម៉ឺនរៀល ឬក៏ ឬក៏លុយដុំ
ដូច្នេះបុរសម្នាក់នោះគាត់ក៏បានអាប់លុយឲ្យស្ត្រីម្នាក់នោះវិញ
គាត់ក៏បានអាប់លុយឲ្យស្ត្រីម្នាក់នោះវិញ អញ្ចឹងស្ត្រីម្នាក់នោះក៏បានលាដៃនិងទទួលលុយអាប់
ពីម៉ូតូឌុបនោះ ពីម៉ូតូឌុបនោះ។ អញ្ចឹងយើងឃើញម៉ូតូឌុបគឺកាន់លុយនៅក្នុងដៃម្ខាង
ដៃម្ខាងទៀតគឺអាប់លុយឲ្យស្ត្រីម្នាក់នោះវិញ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ រូបភាពទី ១៥ ម៉ូតូឌុបក៏បានបើក
ក៏បានបើកចេញត្រលប់ទៅកន្លែងវិញ ឬក៏បានបើកចេញដើម្បីរកភ្ញៀវជិះបន្ត ដើម្បីរកភ្ញៀវទៀត
និងយើងឃើញក្រោយពេលគាត់បើកចេញ
យើងឃើញគាត់បានទម្លាក់កញ្ចក់នៅពេលដែលគាត់បើកម៉ូតូ
នៅពេលដែលគាត់បើកម៉ូតូចេញពីកន្លែងនោះ ដើម្បីរកភ្ញៀវបន្តទៀត ឬក៏ត្រលប់ទៅកន្លែងគាត់វិញ
អញ្ចឹងគាត់បិទកញ្ចក់ និងជិះយ៉ាងលឿនត្រលប់ទៅវិញ
និងស្ត្រីម្នាក់នោះគាត់ក៏បានមកដល់កន្លែងយ៉ាង ដោយសុវត្ថិភាព
បន្ទាប់មកគាត់ក៏បានស្លឹងមើលម៉ោង ឬក៏គាត់បានមើលម៉ោងម្តងទៀត
ដើម្បីឲ្យច្បាស់ថាតើគាត់បានមកដល់ទាន់ពេល  តើគាត់បានមកដល់ទាន់ពេល ឬក៏យឺត
អញ្ចឹងក្រោយពេលដែលម៉ូតូឌុបបានត្រលប់ទៅវិញ ស្ត្រីម្នាក់នោះគាត់ក៏បានដើរទៅមុខ
និងមើលម៉ោងរបស់គាត់ម្តងទៀត

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកគាត់ក៏ បន្ទាប់មកគាត់ក៏បានមកដល់ហាងកាហ្វេមួយនៅក្នុងរូបភាពទី ១៥
នៅក្នុងរូបភាពទី ១៦ អញ្ចឹងរូបភាពទី ១៦ ស្ត្រីម្នាក់នោះក៏បានមកដល់ហាងកាហ្វេមួយ
ដើម្បីជួបជាមួយនឹងភ្ញៀវរបស់គាត់ ឬក៏ដើម្បីជួបជាមួយនឹងពួកម៉ាករបស់គាត់។
ប៉ុន្តែប្រហែលជាគាត់ជួបជាមួយនឹងភ្ញៀវរបស់គាត់ច្រើនជាង
ដោយសារតែគាត់ស្លៀកពាក់មើលទៅឯកសណ្ឋានជាអ្នកធ្វើការ។
អញ្ចឹងប្រហែលជាគាត់មានការប្រជុំ ឬក៏ណាត់ជួបជាមួយភ្ញៀវរបស់គាត់អំពីការងារនៅហាងកាហ្វេ។
ដោយយើងឃើញគាត់ដើរចូល គាត់ដើរចូល តាមទ្វារ តាមទ្វារចូលមកខាងក្នុង
ដើម្បីជួបភ្ញៀវរបស់គាត់ ដោយយើងឃើញមានបុរសម្នាក់នៅខាងក្នុង
ដោយគាត់កំពុងតែអង្គុយញ៉ាំកាហ្វេ ដោយយើងឃើញនៅលើតុរបស់គាត់ មានកាហ្វេ ១ ពែង
និងគាត់អង្គុយនៅលើកៅអី ដែលបុរសម្នាក់នោះពាក់អាវពណ៌ពងមាន់
ដែលយើងមានពណ៌សលាយនឹងពណ៌លឿងដែលយើងហៅថាពណ៌ពងមាន់
និងខោជើងវែងពណ៌ស គាត់ពាក់អាវពណ៌ពងមាន់ដៃខ្លី ខោជើងវែងពណ៌ស ក្រោយពីគាត់
ក្រោយពីគាត់អង្គុយចាំស្ត្រីម្នាក់នោះ គាត់បានញ៉ាំកាហ្វេ គាត់បានញ៉ាំកាហ្វេ
ដើម្បីអង្គុយចាំស្ត្រីម្នាក់នោះ ដើម្បីជជែកគ្នាអំពីការងារ ដើម្បីជជែកគ្នាអំពីការងាររបស់ពួកគាត់
និងនៅពេលដែលស្ត្រីម្នាក់នោះ [...] គាត់ដើរតាម គាត់ដើរចូល គាត់ដើរចូលតាមទ្វារ
គាត់ដើរចូលតាមទ្វាររបស់ហាងកាហ្វេនោះចូលមកខាងក្នុង
ដោយយើងឃើញមានគំនូរជាច្រើនព្យួរនៅលើជញ្ជាំងនៅខាងក្នុង បន្ទាប់មកគាត់ បន្ទាប់មក
គាត់ក៏បានដើរចូលទៅខាងក្នុង និងគាត់បានជួបជាមួយនឹងភ្ញៀវរបស់គាត់
ដែលកំពុងតែអង្គុយរង់ចាំគាត់។ បន្ទាប់មកទៀតគាត់ក៏បានលើកដៃដើម្បីនិយាយសួស្តីទៅកាន់
ទៅកាន់ភ្ញៀវរបស់គាត់ និងភ្ញៀវរបស់គាត់ដែលជាបុរសដែលពាក់អាវពណ៌ពងមាន់ដៃខ្លីនោះ
គាត់ក៏បានលើកដៃទាំងពីរ ដោយទឹកមុខសប្បាយរីករាយ និងត្រេកអរ
ដោយបានជួបជាមួយនឹងស្ត្រីម្នាក់នោះ ប្រហែលជាពួកគាត់ទាំងពីរ គឺជា
គឺជាដៃគូធ្វើការជាមួយគ្នាយ៉ាងល្អ ដូច្នេះពួកគាត់បានណាត់គ្នានៅហាងកាហ្វេនេះ
ដើម្បីជជែកគ្នាអំពីការងាររបស់គាត់ និងស្ត្រីម្នាក់នោះគាត់ក៏បានមកដល់កន្លែងទាន់ពេលវេលា
និងជួបជាមួយនឹងភ្ញៀវរបស់គាត់ និងជួបជាមួយនឹងភ្ញៀវរបស់គាត់ ដោយមិនបាន
ដោយមិនបានខកខាន ដោយមិនបានខក ដោយមិនបានខកខាន ពីព្រោះប្រសិនបើគាត់មកយឺត
គាត់នឹងខកខានជួបជាមួយភ្ញៀវរបស់គាត់ ដោយសារតែ នៅពេលដែលភ្ញៀវរបស់គាត់រង់ចាំយូរ
ភ្ញៀវរបស់គាត់នឹងអាចចាកចេញពីហាងនោះ ដោយសារតែ
ប្រហែលជាគាត់នឹងមានការងារដែលត្រូវធ្វើផង ដូច្នេះគាត់មិនអាចអង្គុយរង់ចាំយូរបានទេ
អញ្ចឹងស្ត្រីម្នាក់នោះគាត់បានមកដល់ទាន់ពេលវេលា និងបានជួបជាមួយនឹងភ្ញៀវរបស់គាត់
ដើម្បីជជែកគ្នាអំពីការងារនៅហាងកាហ្វេមួយ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.